ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០០១/២០ សជណ.អ.ប.ព.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌថ្មីឱ្យចូលបម្រើការងារក្នុងក្របខណ្ឌ អង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ឆ្នាំ២០២០

**យោង៖** លិខិតលេខ ៥៧៤៥ មស.ក្រខ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ ។

អង្គភាពប្រឆាំងអំពើពុករលួយ សូមជូនដំណឹងដល់សិស្ស-និស្សិត និងមន្ត្រីជាប់កិច្ចសន្យា ដែលកំពុងបម្រើការងារនៅអង្គភាពប្រឆាំងអំពើពុករលួយឱ្យបានជ្រាបថា ឆ្នាំ២០២០ នេះ អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) នឹងធ្វើការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌថ្មី ចំនួន ៧៥ កន្លែង ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌ អ.ប.ព. ដោយត្រូវកំណត់លក្ខខណ្ឌដូចខាងក្រោម៖

**ក-ក្របខណ្ឌត្រូវជ្រើសរើស**

១- ថ្នាក់កណ្តាល **ចំនួន ៥១ កន្លែង**

២- ថ្នាក់ខេត្ត **ចំនួន ២៤ កន្លែង** ដែលត្រូវបានធ្វើការបែងចែកដូចខាងក្រោមៈ

- **ក្រុមខេត្តទី១** : ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តតាកែវ មានការិយាល័យប្រចាំការនៅខេត្តកណ្តាល ចំនួន ៤ កន្លែង
- **ក្រុមខេត្តទី២** : ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង មានការិយាល័យប្រចាំការនៅខេត្តព្រះសីហនុ ចំនួន ៤ កន្លែង
- **ក្រុមខេត្តទី៣** : ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់ មានការិយាល័យប្រចាំការនៅខេត្តកំពង់ឆ្នាំង ចំនួន ៣ កន្លែង
- **ក្រុមខេត្តទី៤** : ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន មានការិយាល័យប្រចាំការនៅខេត្តបាត់ដំបង ចំនួន ៣ កន្លែង
- **ក្រុមខេត្តទី៥** : ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ មានការិយាល័យប្រចាំការនៅខេត្តសៀមរាប ចំនួន ៣ កន្លែង
- **ក្រុមខេត្តទី៦** : ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តត្បូងឃ្មុំ មានការិយាល័យប្រចាំការនៅខេត្តកំពង់ចាម ចំនួន ៣ កន្លែង
- **ក្រុមខេត្តទី៧** : ខេត្តក្រចេះ ខេត្តមណ្ឌលគីរី ខេត្តរតនគីរី និងខេត្តស្ទឹងត្រែង មានការិយាល័យប្រចាំការនៅខេត្តក្រចេះ ចំនួន ៤ កន្លែង ។

**ខ-លក្ខខណ្ឌជ្រើសរើស**

១- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ

២- លក្ខខណ្ឌអាយុ (គិតត្រឹមថ្ងៃប្រឡង)

- បេក្ខជន ដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ



*អគារលេខ ៥៤ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ*
Website: www.acu.gov.kh, E-mail: complaint@acu.gov.kh, info@acu.gov.kh
Tel: 023 223 954, 023 221 653, Hotline: 1282

- បេក្ខជន ដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ ឆ្នាំ
- បេក្ខជន ដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ ឆ្នាំ
- បេក្ខជន ដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៨ ឆ្នាំ
- បេក្ខជន ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៥ ឆ្នាំ ។

៣- មិនបានប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិជាពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។

**គ-សំណុំលិខិតចុះឈ្មោះសុំសិទ្ធិប្រឡង**

| | |
|---|---|
| ១- ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ១ ច្បាប់ |
| ២-ប្រវត្តិរូប *(មានបិទរូបថតថ្មី និងផ្ទៃពណ៌ខៀវ ទំហំ 4x6)* | ចំនួន ១ ច្បាប់ |
| ៣-សលាកបត្រឯកត្តជន | ចំនួន ១ ច្បាប់ |
| ៤- បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ចំនួន ១ ច្បាប់ |
| ៥- សេចក្តីចម្លងសញ្ញាបត្រ | ចំនួន ១ ច្បាប់ |
| ៦- សេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ចំនួន ១ ច្បាប់ |
| ៧-លិខិតថ្កោលទោស *(ក្រោយពេលប្រឡងជាប់)* | ចំនួន ១ ច្បាប់ |
| ៨- លិខិតពិនិត្យសុខភាព *(ក្រោយពេលប្រឡងជាប់)* | ចំនួន ១ ច្បាប់ |
| ៩- រូបថតថ្មី *(ផ្ទៃពណ៌ខៀវ 4x6)* | ចំនួន ១ សន្លឹក ។ |

**ឃ-ការដាក់ពាក្យសុំចូលរួមប្រឡងប្រជែង / កាលបរិច្ឆេទទទួលពាក្យសុំសិទ្ធិប្រឡង**

បេក្ខជនត្រូវមកទទួលពាក្យ និងដាក់ពាក្យសុំសិទ្ធិប្រឡងនៅ អ.ប.ព. រៀងរាល់ថ្ងៃ (ពីថ្ងៃចន្ទ ដល់ ថ្ងៃអាទិត្យ និងថ្ងៃបុណ្យ) ព្រឹកចាប់ពីម៉ោង ៧:៣០ - ១១:៣០ និងរសៀលចាប់ពីម៉ោង ១៤:០០ - ១៧:០០ **ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០** ។

បេក្ខជនត្រូវបង់ថ្លៃសំណុំឯកសារដាក់ពាក្យប្រឡងចំនួន ៥.០០០ (ប្រាំពាន់) រៀល/ច្បាប់ និងបង់ថ្លៃសម្រាប់សុំសិទ្ធិប្រឡងចំនួន ៣៥.០០០ (បីម៉ឺនប្រាំពាន់) រៀល/ច្បាប់ ។

➢ **បញ្ជាក់**:

- ❖ រាល់លិខិតស្នាមពាក់ព័ន្ធ ត្រូវមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ និងត្រូវយកមកជាមួយនូវច្បាប់ដើមដើម្បីធ្វើការផ្ទៀងផ្ទាត់
- ❖ ក្រោយពីប្រឡងជាប់ជាមន្ត្រីរាជការ នៃ អ.ប.ព. បេក្ខជនទាំងអស់ត្រូវគោរពអនុវត្តតាមបទប្បញ្ញត្តិផ្ទៃក្នុង អ.ប.ព. ដូចជា:
  - ស្ម័គ្រចិត្តទទួលការពិនិត្យដោយឧបករណ៍ប៉ូលីក្រាហ្វ (POLYGRAPH) ដើម្បីវាស់ស្ទង់ចម្លើយកុហក និងធ្វើតេស្តរកសារធាតុញៀនតាមការកំណត់របស់អង្គភាព
  - សុំច្បាប់អនុញ្ញាតជាមុនរាល់ការទទួលទានអាហារ និងភេសជ្ជៈក្រៅពីរង្វង់គ្រួសារ
  - អនុវត្តគោលការណ៍ក្នុងការហូបបាយជាមួយសហការី (**បាយឝុស្ស៊ីៈ** ចេញលុយស្មើគ្នា ឬ **បាយ អ.ប.ព.**: អ្នកមានឋានៈធំជាងគេជាអ្នកចេញលុយ)
  - ត្រូវរាយការណ៍ និងសុំការអនុញ្ញាតអំពីការទទួលអំណោយ ដែលគេប្រគល់ឱ្យដែលមានតម្លៃលើសពី១០ ម៉ឺនរៀល
  - រក្សានូវការសម្ងាត់វិជ្ជាជីវៈក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន (ទោះក្រោយពេលលាឈប់ ឬត្រូវបានបញ្ឈប់ពីអង្គភាព ឬ ត្រូវចូលនិវត្តន៍)

- ខិតខំការពារ ថែរក្សាទ្រព្យសម្បត្តិរបស់អង្គភាព និងខិតខំបំពេញភារកិច្ចដែលអង្គភាពប្រគល់ជូន
- ផ្តាច់គ្រប់ទំនាក់ទំនង (ទូរស័ព្ទ ...) ក្នុងពេលចូលរួមប្រតិបត្តិការ រហូតដល់ចប់បេសកកម្ម
- គោរពអនុវត្តបទប្បញ្ញត្តិផ្សេងៗទៀត និងបទប្បញ្ញត្តិថ្មីៗដែលអង្គភាពដាក់ចេញ ។

មុខវិជ្ជាប្រឡង កាលបរិច្ឆេទ និងមណ្ឌលប្រឡង និងបញ្ជីរាយនាមបេក្ខជន គណៈកម្មការរៀបចំការប្រឡង នឹងជូនដំណឹងនៅពេលក្រោយ ៕

ថ្ងៃ អង្គារ ៥ រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០

ទេសរដ្ឋមន្ត្រី
ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ
និងជាប្រធានគណៈកម្មការរៀបចំការប្រឡង

បណ្ឌិត ឱម យ៉ិនទៀង

**លេខទូរស័ព្ទទំនាក់ទំនង :**

-កញ្ញា ទេព ច័ន្ទសុគន្ធា 092 555 418
-លោក ផន សំអុន 078 999 193 / 016 987 168
-លោក ឆែម តារា 085 996 650 / 069 704 900